# ការបំពេញពាក្យសុំជំនួយអាហារ

## *តើវាជាអ្វី?*

ពាក្យសុំជំនួយអាហារ (Meal Benefit Application) គឺជាពាក្យសុំសម្ងាត់ សម្រាប់ប្រើក្នុងការកំណត់ភាពមានសិទ្ធិទទួលបានអាហារសាលាដោយឥតគិតថ្លៃ ឬទទួលបានអាហារដោយបញ្ចុះតម្លៃ ចំពោះសិស្ស ។ សាលារៀនមូលដ្ឋាន ស្នើសុំឲ្យ មាតាបិតា/អាណាព្យាបាលសិស្ស បំពេញព័ត៌មានក្នុងពាក្យសុំនេះ នៅដើមឆ្នាំសិក្សានីមួយៗ ដើម្បីជាជំនួយក្នុងការពិនិត្យមើលប្រាក់ចំណូលរបស់គ្រួសារសិស្ស និងសហគមន៍ ។

## *តើហេតុអ្វីបានជាវាមានសារៈសំខាន់?*

ការបំពេញពាក្យសុំជំនួយស្បៀងអាហារ សម្រាប់គ្រួសារអ្នក គឺជាវិធីងាយមួយក្នុងការវិនិយោគចំពោះការសិក្សា ក្នុងសហគមន៍របស់អ្នក បើទោះបីជាអ្នកគិតថា ខ្លួនមិនមានលក្ខណៈសម្បត្តិអាចទទួលបានជំនួយនេះក៏ដោយចុះ ។ ទិន្នន័យអំពីប្រាក់ចំណូលក្នុងគ្រួសារ ដែលប្រមូលបានពីក្នុងពាក្យសុំនេះ អាចយកមកប្រើជាគន្លឹះចំពោះធនធានសម្រាប់ប្រើចំពោះការសិក្សា ហើយក៏សម្រាប់យកមកប្រើក្នុងការបង្វែរជំនួយផ្សេងទៀតដល់គ្រួសារណា ដែលអាចត្រូវការជំនួយនេះ ។

## *របៀបបំពេញពាក្យសុំ ៖*

ពាក្យសុំនេះ មានផ្តល់ជូនតាមរយៈកម្មវិធីអាហាររូបតម្ភតាមសាលារៀន នៃសាលារៀនប្រចាំឱស្រ្តិកក្នុងមូលដ្ឋានរបស់ អ្នក ។ តែក៏មានឱស្រ្តីកមួយចំនួនអាចឲ្យអ្នកបំពេញពាក្យ សុំនេះតាមអនឡាញដែរ ។ ពាក្យសុំជាក្រដាស ក៏នឹងមានផ្តល់ជូនដែរ ។ នេះគឺជាផ្នែកមួយនៃឯកសារដែលអ្នកត្រូវបំពេញ នៅពេលចាប់ផ្តើមឆ្នាំសិក្សា ដែលសាលានឹងផើតាមកនរបស់អកឲយេកមកផះ ។

## កម្មវិធីនានាដែលទទួលថវិកាដោយការប្រើទិន្នន័យពីពាក្យសុំជំនួយស្បៀងអាហារ ៖

កម្មវិធីថវិកាអាហារសាលារបស់សហព័ន្ធ មានផ្តល់ជូនថវិកាសម្រាប់កម្មវិធីសាលាជាច្រើន ។ កម្មវិធីនេះ ផ្តល់អត្ថប្រយោជន៍ដល់សិស្ស *ទាំងអស់* ក្នុងរដ្ឋមេន ។ កម្មវិធីទាំងអស់នេះ មានជាអាទិ៍ ៖

- សាលារៀន Title 1
- ច្បាប់ការអប់រំបឋម និងមធ្យមសិក្សា (ESEA, Elementary & Secondary Education Act)
- ច្បាប់ជនមានពិការភាពជាប់ខ្លួន (IDEA, Individuals with Disabilities Act)
- ថវិការដ្ឋសម្រាប់ឧបត្ថម្ភសាលា
- មុន/ក្រោយកម្មវិធីសាលា
- កម្មវិធីសាលានៅរដូវក្តៅ
- កម្មវិធីសិក្សា និងឱកាសទទួលបានថវិកា ដែលជាគំនិតផ្តួចផ្តើមរបស់នាយកដ្ឋានសិក្សាធិការប្រចាំរដ្ឋមេន
- ការលើកលែងមិនទារប្រាក់កម្ចី គ្រូសិស្ស






Maine
Department of
Education

## ការភ្ជាប់ទំនាក់ទំនងចំពោះសេវាកម្មសំខាន់សម្រាប់គ្រួសារ

បើគ្រួសារអ្នកស្ថិតក្រោមគោលការណ៍ណែនាំក្នុងការទទួលបានអាហារឥតគិតថ្លៃ/បញ្ចុះតម្លៃ អ្នកក៏អាចទទួលបានជំនួយអាហារូបត្ថម្ភបន្ថែម តាមរយៈកម្មវិធីជំងឺឆ្លងសកល(P-EBT, Pandemic EBT)ផងដែរ! ដោយការបំពេញពាក្យសុំនេះឲ្យបានត្រឹមថ្ងៃទី 31 ខែសីហា ឆ្នាំ 2021 គឺអ្នកអាចមានសិទ្ធិទទួលបានប្រាក់ជំនួយរដូវក្តៅពីកម្មវិធី P-EBT និងការផ្តល់ជំនួយបែបនេះនាពេលខាងមុខផងដែរ ក្នុងអំឡុងឆ្នាំសិក្សា 2021/2022 ។